

តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia

# សេចក្តីសង្ខេប ស្តីពី ធុរកិច្ច

- កតិកាសញ្ញាសុចរិតភាព
- ការរួមវិភាគទានផ្នែកនយោបាយ
- ការសច្ចាប្រព្រឹត្តសុចរិតភាព
- អំណោយសប្បុរសធម៌ និងការឧបត្ថម្ភ

លោក ប៉ិច ពិសី
នាយកកម្មវិធីជាន់ខ្ពស់
អង្គការតម្លាភាពកម្ពុជា
piseypech@ticambodia.org

អង្គការតម្លាភាពកម្ពុជា
អាសយដ្ឋាន ៖ ផ្ទះលេខ៣ ផ្លូវ៣៩០ សង្កាត់បឹងកេងកង៣
ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០២៣ ២១៤ ៤៣០
គេហទំព័រក្នុងប្រទេស ៖ www.ticambodia.org
គេហទំព័រនៅការិយាល័យកណ្ដាល៖ www.transparency.org

តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia

អង្គការតម្លាភាពកម្ពុជា គឺជាសាខាក្នុងប្រទេសមួយដែលមានការទទួលស្គាល់ពេញលេញរបស់អង្គការតម្លាភាពអន្តរជាតិ និងត្រូវបានបង្កើតឡើងជាផ្លូវការនៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ ២០១០ ដោយសកម្មជនប្រឆាំងអំពើពុករលួយ និងអ្នកជំនាញជាច្រើនដែលប្ដេជ្ញាបង្កើតសង្គមកម្ពុជាប្រកបដោយតម្លាភាព និងគណនេយ្យភាព។ ចាប់ពីពេលនោះមក អង្គការនេះបានបង្កើតជាស្ថាប័នដ៏រឹងមាំមួយ ដែលប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ និងលើកកម្ពស់សុចរិតភាព តម្លាភាព និងគណនេយ្យភាពក្នុងប្រទេស។

យើងធ្វើការជាមួយបុគ្គល និងស្ថាប័នជាច្រើននៅគ្រប់កម្រិត ដូចជា រដ្ឋាភិបាល សង្គមស៊ីវិល អាជីវកម្ម ប្រព័ន្ធផ្សព្វផ្សាយ និងសាធារណជនដើម្បីសម្រេចបានការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព លើកកម្ពស់សុចរិតភាព និងប្រឆាំងអំពើពុករលួយ។

ឯកសារនេះត្រូវបានរៀបរៀងឡើង ក្រោមជំនួយថវិការបស់សហភាពអឺរ៉ុប ប្រទេសស៊ុយអែតនិងប្រទេសស្វីស។ រាល់ខ្លឹមសារនៅក្នុងឯកសារនេះពុំឆ្លុះបញ្ចាំងពីទស្សនៈសហភាពអឺរ៉ុបប្រទេសស៊ុយអែត ឬ ប្រទេសស្វីសឡើយ។

SWEDEN

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

# មាតិកា

## ផ្នែកទី១៖
## កតិកាសញ្ញាសុចរិតភាព


I. និយមន័យ
II. គោលនយោបាយ និងនីតិវិធី
III. ការដាក់ទណ្ឌកម្មចំពោះភាពមិនអនុលោម
IV. ការដោះស្រាយវិវាទ
V. អត្ថប្រយោជន៍


## ផ្នែកទី២៖
## ការរួមវិភាគទានផ្នែកនយោបាយ


I. និយមន័យ
II. គោលនយោបាយ និងនីតិវិធី
III. អត្ថប្រយោជន៍


## ផ្នែកទី៣៖
## ការសច្ចាប្រព្រឹត្តសុចរិតភាព


I. និយមន័យ
II. គោលការណ៍ និងបម្រាមនៃការសច្ចាប្រព្រឹត្តសុចរិតភាព
III. ការដាក់ទណ្ឌកម្មចំពោះភាពមិនអនុលោម
IV. អត្ថប្រយោជន៍នៃការមាន និងការអនុវត្តការសច្ចាប្រព្រឹត្តសុចរិតភាព


## ផ្នែកទី៤៖
## អំណោយសប្បុរសធម៌ និងការឧបត្ថម្ភ


I. និយមន័យ
II. គោលនយោបាយ និងនីតិវិធី
III. អត្ថប្រយោជន៍

# ផ្នែកទី១
# កតិកាសញ្ញាសុចរិតភាព

តើអ្នកធ្លាប់ឆ្ងល់ទេថា ហេតុអ្វីបានជាក្រុមហ៊ុន ឬសមាគមធុរកិច្ចចំណាយលុយច្រើនដល់អ្នកផ្គត់ផ្គង់ ឬ អ្នកម៉ៅការនៅពេលពួកគេត្រូវការទិញទំនិញ ឬ សេវាកម្មណាមួយ? ការចំណាយខ្លះលើសពីតម្លៃទីផ្សារសម្រាប់ផលិតផលទំនិញ ឬសេវាកម្មដែលមានគុណភាពដូចគ្នា។ តើមានការឃុបឃិតក្នុងចំណោមអ្នកប្រកួតប្រជែង ឬ អ្នកដេញថ្លៃដែរឬទេដើម្បីទទួលបានកិច្ចសន្យា ឬតើសកម្មភាពលទ្ធកម្មនីមួយៗមិនមានតម្លាភាព ឬយ៉ាងណា?

យន្តការដ៏មានប្រសិទ្ធភាពមួយ ដើម្បីជួយដល់រាជរដ្ឋាភិបាល ធុរកិច្ចនានា និងសង្គមស៊ីវិលប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយក្នុងការផ្ដល់កិច្ចសន្យា រវាងក្រុមហ៊ុន និងអ្នកដេញថ្លៃ គឺការអនុវត្តកតិកាសញ្ញាសុចរិតភាព។ អត្ថបទសង្ខេបអំពី ធុរកិច្ចនេះ នឹងផ្ដល់ឱ្យក្រុមហ៊ុនស្ថាប័នរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិល នូវការណែនាំ អំពីកតិកាសញ្ញាសុចរិតភាព ដោយកំណត់នូវអ្វីជាកតិកាសញ្ញាសុចរិតភាពគោលនយោបាយ និងនីតិវិធីនៃកតិកាសញ្ញាសុចរិតភាព ការដាក់ទណ្ឌកម្ម ដែលអាចមានសម្រាប់ ការមិនអនុលោមតាម និងផលប្រយោជន៍នៃការអនុវត្តកតិកាសញ្ញាសុចរិតភាព។

### តើកតិកាសញ្ញាសុចរិតភាពគឺជាអ្វី?

កតិកាសញ្ញាសុចរិតភាព គឺជាកិច្ចព្រមព្រៀងមួយដែលមានបំណងរកឱ្យឃើញនិង បង្ការអំពើពុករលួយក្នុងការរៀបចំផ្ដល់កិច្ចសន្យាសាធារណៈ។ វាគឺជាកិច្ចព្រមព្រៀងមួយរវាងស្ថាប័នធ្វើលទ្ធកម្ម និងអ្នកផ្គត់ផ្គង់សេវារបស់ខ្លួនដោយភាគីមួយតំណាងឱ្យអាជ្ញាធរ ហើយភាគីម្ខាងទៀតអាចជាក្រុមហ៊ុនឯកជនដែលចាប់អារម្មណ៍ក្នុងការទទួលកិច្ចសន្យា ដែលភាគីទាំងពីរនេះនឹងត្រូវចៀសវាងពីការអនុវត្តការសូកប៉ាន់ ការឃុបឃិត និងការប្រព្រឹត្តអំពើពុករលួយនានានៅពេលបំពេញខ្លឹមសារ និងលក្ខខណ្ឌនៃកិច្ចសន្យា។ វាគឺជាឧបករណ៍មួយដើម្បីទប់ស្កាត់ហានិភ័យនៃអំពើពុករលួយនៅក្នុងដំណើរការរៀបចំផ្ដល់កិច្ចសន្យា។

កតិកាសញ្ញាសុចរិតភាព ត្រូវអនុលោមទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ហើយកិច្ចព្រមព្រៀងនេះត្រូវធ្វើឡើងដោយសុឆន្ទៈ ដោយគ្រប់ភាគីពាក់ព័ន្ធទាំងអស់ និងចងកាតព្វកិច្ចតាមផ្លូវច្បាប់ ។

លទ្ធកម្ម និងការរៀបចំផ្តល់កិច្ចសន្យាមានការប្រឈមខ្ពស់ទៅនឹងហានិភ័យនៃអំពើពុករលួយ ។ ការលេចធ្លាយព័ត៌មាន អាចកើតឡើងនៅគ្រប់ដំណាក់កាល នៃកិច្ចលទ្ធកម្ម និងដំណើរការរៀបចំផ្តល់កិច្ចសន្យា ក្នុងនោះរួមមាន រយៈពេលមុនដំណាក់កាលរៀបចំកិច្ចសន្យាអំឡុងពេលដេញថ្លៃ និងការអនុវត្តលក្ខខណ្ឌនិងកាតព្វកិច្ចផ្សេងៗនៃកិច្ចសន្យា ។

កតិកាសញ្ញាសុចរិតភាព កំណត់អំពីសិទ្ធិ និងកាតព្វកិច្ចនានា ក្នុងកម្រិតវិសាលភាពថាភាគីណាមួយក៏ដោយមិនត្រូវចំណាយ ផ្តល់ ទាមទារ ឬទទួលយកសំណូកហើយអ្នកដេញថ្លៃ មិនត្រូវឃុបឃិតជាមួយដៃគូប្រកួតប្រជែង ដើម្បីទទួលបានកិច្ចសន្យាឬសូកអ្នកតំណាងរបស់អាជ្ញាធរនៅពេលដែលកំពុងអនុវត្តដំណើរការដេញថ្លៃឡើយ ។ លើសពីនេះទៀតកាតព្វកិច្ចដទៃទៀតអាចត្រូវបានរាប់បញ្ចូល ដូចជា តម្រូវការឱ្យអ្នកដេញថ្លៃបង្ហាញពីកម្រៃជើងសារទាំងអស់ ឬការចំណាយស្រដៀងគ្នាដែលបានបង់ទៅឱ្យនរណាម្នាក់ពាក់ព័ន្ធនឹងកិច្ចសន្យា ឬតម្រូវឱ្យមន្ត្រីរដ្ឋាភិបាល ដែលជាប់ពាក់ព័ន្ធក្នុងដំណើរការនេះត្រូវតែប្តេជ្ញាអនុវត្តតាមក្រមសីលធម៌ ស្របតាមស្មារតីនៃកតិកាសញ្ញាសុចរិតភាព ។



រក្សាសិទ្ធិរូបភាពដោយ Creative Common, Jean-Pierre Dalbéra

## គោលនយោបាយ និងនីតិវិធីស្ដីពីកតិកាសញ្ញាសុចរិតភាព

> គោលនយោបាយនេះអាចអនុវត្តបាន ចំពោះសកម្មភាពកិច្ចសន្យារបស់ក្រុមហ៊ុន ដែលមានរយៈពេលច្រើនជាងបីខែ ឬលទ្ធកម្មទោលណាមួយដែលមានតម្លៃលើសពី ៥,000

កតិកាសញ្ញាសុចរិតភាព ត្រូវចុះហត្ថលេខានៅដំណាក់កាលដំបូងបំផុតនៃទំនាក់ទំនងរវាងក្រុមហ៊ុន និងអ្នកផ្គត់ផ្គង់សេវារបស់ខ្លួន ហើយបន្ទាប់មកនឹងត្រូវចុះហត្ថលេខាជារៀងរាល់ឆ្នាំសម្រាប់កិច្ចសន្យាដែលមានរយៈពេលលើសពីមួយឆ្នាំ ។ សម្រាប់ការអញ្ជើញឱ្យចូលរួមដេញថ្លៃកតិកាសញ្ញាសុចរិតភាពតម្រូវឱ្យមានការចុះហត្ថលេខា និងត្រូវដាក់បញ្ចូលទៅក្នុងការដាក់ពាក្យស្នើសុំដេញថ្លៃដោយអ្នកដេញថ្លៃនីមួយៗ ។

សម្រាប់ទម្រង់ដទៃទៀតនៃកិច្ចលទ្ធកម្ម កតិកាសញ្ញាសុចរិតភាពតម្រូវឱ្យមានការចុះហត្ថលេខានៅពេលដាក់សំណើតម្លៃ ពេលចុះកិច្ចព្រមព្រៀងនៃលក្ខខណ្ឌកិច្ចសន្យា ពេលចុះកិច្ចព្រមព្រៀងនៃការបញ្ជាទិញ ឬឯកសារផ្សេងៗទៀត ដែលអ្នកធ្វើលទ្ធកម្មយល់ឃើញថាសមស្រប ។ ប្រសិនបើមិនច្បាស់លើចំណុចណាមួយក្នុងការណែនាំរបស់កតិកាសញ្ញាសុចរិតភាព ជាការល្អបំផុតអ្នកធ្វើលទ្ធកម្មត្រូវពិភាក្សាចំណុចទាំងនោះជាមួយប្រធានគ្រប់គ្រងផ្នែកសុចរិតភាព ។

អ្នកធ្វើលទ្ធកម្មមានភារកិច្ចពន្យល់ពីលក្ខខណ្ឌ និងកាតព្វកិច្ចនានាដល់អ្នកម៉ៅការអ្នកផ្ដល់សេវា និងអ្នកផ្គត់ផ្គង់ មុនពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀង ។

អ្នកធ្វើលទ្ធកម្មត្រូវទទួលខុសត្រូវក្នុងការធានាថា កតិកាសញ្ញាសុចរិតភាព ត្រូវបានដាក់បញ្ចូលក្នុងកិច្ចព្រមព្រៀងលទ្ធកម្ម និងកិច្ចព្រមព្រៀងផ្ដល់កិច្ចសន្យាហើយកិច្ចព្រមព្រៀងនេះត្រូវចុះហត្ថលេខាដោយអ្នកម៉ៅការ អ្នកផ្ដល់សេវា និងអ្នកផ្គត់ផ្គង់ ហើយបន្ទាប់មក ត្រូវចុះហត្ថលេខាជាថ្មីម្ដងទៀតជារៀងរាល់ឆ្នាំសម្រាប់កិច្ចសន្យាដែលមានរយៈពេលលើសពី១ឆ្នាំ ។

# ការដាក់ទណ្ឌកម្មចំពោះភាពមិនអនុលោម

ប្រសិនបើអ្នកផ្តល់សេវាត្រូវបានគេរកឃើញថា បំពានលើខ្លឹមសារ និង លក្ខខណ្ឌនៃកតិកាសញ្ញាសុចរិតភាព ក្រុមហ៊ុនអាចអនុវត្តតាមឆន្ទានុសិទ្ធដាច់ខាត នៅក្នុងទំហំមួយដែលបានអនុញ្ញាតដោយច្បាប់ លើការដាក់ទណ្ឌកម្មណាមួយ ឬទាំងអស់ ដូចខាងក្រោម៖

ការបដិសេធ ឬការលុបចោលកិច្ចសន្យា

គ្មានការបង់ថ្លៃ/ការចំណាយណាមួយ

ទទួលខុសត្រូវចំពោះការខូចខាតទៅលើក្រុមហ៊ុន រហូតដល់កម្រិតអតិបរមា ១០០% នៃតម្លៃកិច្ចសន្យា។

ប្រគល់ជូនវិញនូវប្រាក់កក់ ប័ណ្ណដេញថ្លៃនិង/ឬ ប័ណ្ណប្រតិបត្តិការផ្សេងៗទៀត។

ការដកក្រុមហ៊ុន និងនាយករបស់ក្រុមហ៊ុនចេញពីការពិចារណាសម្រាប់កិច្ចសន្យាពេលអនាគតសម្រាប់រយៈពេលមួយ រហូតដល់ក្រុមហ៊ុនទាំងនេះអាចមានលក្ខណៈសម្បត្តិសមស្របឡើងវិញ។

និងរាយការណ៍អំពីករណីនេះដល់អង្គភាពប្រឆាំងអំពើពុករលួយ និង/ឬ អាជ្ញាធរពាក់ព័ន្ធដទៃទៀត។



រក្សាសិទ្ធិរូបភាពដោយ Creative Common, Michael Clarke Stuff

# ការដោះស្រាយវិវាទ

ក្នុងករណីមានវិវាទកើតឡើងនៅក្នុងការអនុវត្តលក្ខខណ្ឌនៅក្នុងកតិកាសញ្ញាសុចរិតភាពភាគីពាក់ព័ន្ធទាំងអស់ត្រូវយល់ព្រមឱ្យមានអាជ្ញាកណ្តាលមួយ ។

ក្នុងករណីមានមជ្ឈត្តកម្ម អង្គជំនុំជម្រះមួយនឹងត្រូវបង្កើតឡើងដើម្បីដោះស្រាយវិវាទ ។ អង្គជំនុំជម្រះនេះត្រូវមានមជ្ឈត្តករចំនួនបីនាក់ ។ ភាគីនីមួយៗអាចជ្រើសរើសមជ្ឈត្តករម្នាក់ ហើយអ្នកទីបី ត្រូវតែជាមជ្ឈត្តករឯករាជ្យដែលបានទទួលការយល់ព្រមពីមជ្ឈត្តករដែលត្រូវបានតែងតាំងទាំងពីរ ។

ទីកន្លែងនៃការអនុវត្តធ្វើមជ្ឈត្តកម្ម ត្រូវធ្វើឡើងនៅកន្លែងមួយដែលជ្រើសរើសដោយអង្គជុំនំជម្រះមជ្ឈត្តកម្ម ។

ភាសាមជ្ឈត្តកម្ម ត្រូវតែជាភាសាអង់គ្លេស ។

រាល់វិវាទដែលទាក់ទងទៅនឹងការរៀបចំទាំងនេះ ត្រូវដោះស្រាយតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ក្រោមវិធាននៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦ ។

សេចក្តីសម្រេចរបស់អង្គជំនុំជម្រះនេះនឹងក្លាយជាសេចក្តីសម្រេចចុងក្រោយ និងចងកាតព្វកិច្ចចំពោះគ្រប់ភាគីទាំងអស់ ។

ការចំណាយលើមជ្ឈត្តកម្ម នឹងត្រូវចែកស្មើគ្នាដោយភាគីវិវាទទាំងសងខាងជាមួយនឹងតម្លៃដែលបានដាក់ស្នើឡើងដោយអង្គជំនុំជម្រះ ដែលបានឯកភាពព្រមព្រៀងគ្នាមុនពេលចាប់ផ្តើមដំណើរការមជ្ឈត្តកម្មនេះ ។

# អត្ថប្រយោជន៍នៃការមាន និងការអនុវត្តគោលនយោបាយស្តីពីកតិកាសញ្ញាសុចរិតភាព

ក្រៅពីជួយធានាបាននូវដំណើរប្រតិបត្តិការស្អាតស្អំរវាងអ្នកម៉ៅការនិងក្រុមហ៊ុនក្នុងអំឡុងពេលប្រតិបត្តិគម្រោង កតិកាសញ្ញាសុចរិតភាពក៏ផ្តល់ផលប្រយោជន៍ផ្សេងៗទៀតផងដែរ។

កតិកាសញ្ញាសុចរិតភាព ផ្តល់នូវលទ្ធភាពទទួលបានព័តិមានកាន់តែប្រសើរឡើង និងបង្កើនកម្រិតតម្លាភាពក្នុងកិច្ចសន្យា។ ជាលទ្ធផលវានាំឱ្យមានការជឿជាក់ និងការជឿទុកចិត្តកាន់តែច្រើន ក្នុងការធ្វើសេចក្តីសម្រេចចិត្ត មិនសូវមានការចោទប្រកាន់អំពីដំណើរការលទ្ធកម្ម និងទទួលបានអ្នកដេញថ្លៃកាន់តែច្រើនចូលរួមប្រកួតប្រជែងដើម្បីទទួលបានកិច្ចសន្យា។

បង្ការបុគ្គលិកពីការប្រព្រឹត្តអំពើពុករលួយក្នុងលទ្ធកម្មដែលក្នុងនោះរួមមានរយៈពេលរៀបចំមុនពេលផ្តល់កិច្ចសន្យាការអញ្ជើញឱ្យចូលរួមដេញថ្លៃនិងការអនុវត្តខ្លឹមសារ និងលក្ខខណ្ឌនានាក្នុងកិច្ចសន្យា។

លើកកម្ពស់ប្រតិបត្តិការស្អាតស្អំរបស់ក្រុមហ៊ុនធ្វើលទ្ធកម្ម និងអ្នកផ្តល់ទំនិញអ្នកផ្គត់ផ្គង់របស់ពួកគេ ក្នុងអំឡុងពេលប្រតិបត្តិគម្រោង។

ធានានូវតម្លាភាព និងប្រសិទ្ធភាពកាន់តែប្រសើរឡើងក្នុងការផ្តល់កិច្ចសន្យា និងកិច្ចលទ្ធកម្ម។

កតិកាសញ្ញាសុចរិតភាព ក៏អាចលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរក្នុងស្ថាប័នផងដែរ ដូចជាការបង្កើនការប្តេជ្ញាចិត្តក្នុងការចែករំលែកទិន្នន័យក្នុងទម្រង់មួយដែលបើកចំហពិតប្រាកដនីតិវិធីរដ្ឋបាលងាយៗ និងសកម្មភាពច្បាប់ដែលមានការកែលម្អ។

សម្រាប់ព័តិមានបន្ថែម និងដើម្បីទទួលបានការគាំទ្រលើការធ្វើសេចក្តីព្រាងស្តីពីគោលនយោបាយនៃកតិកាសញ្ញាសុចរិតភាព សម្រាប់ក្រុមហ៊ុនរបស់អ្នក សូមទាក់ទងមកកាន់៖ piseypech@ticambodia.org ។

# ផ្នែកទី២៖
# ការរួមវិភាគទានផ្នែកនយោបាយ

នៅក្នុងសង្គមប្រជាធិបតេយ្យមួយ ប្រជាពលរដ្ឋចាំបាច់ត្រូវចូលរួមនៅក្នុងនយោបាយ និងដំណើរការធ្វើការសេចក្ដីសម្រេច។ អ្នកត្រូវចាត់ទុកខ្លួនអ្នកជាពលរដ្ឋសកម្ម និងពលរដ្ឋមួយរូបដែលមានភាពពាក់ព័ន្ធ។ អ្នកប្រហែលជាចង់គាំទ្របុព្វហេតុនយោបាយនានា និងបង្ហាញចំណាប់អារម្មណ៍របស់ក្រុមហ៊ុនអ្នកថាជាអ្នកគាំទ្រផងដែរ។ បើទោះបីវាជាការល្អក្នុងការគាំទ្រដល់បុព្វហេតុដែលអ្នកស្រលាញ់ចូលចិត្តក៏ដោយ ប៉ុន្តែ ជួនកាលការរួមវិភាគទានផ្នែកនយោបាយអាចធ្វើឱ្យអ្នកជួបបញ្ហា ប្រសិនបើសកម្មភាពរបស់អ្នកត្រូវបានគេយល់ថាជាការសូកប៉ាន់។

ការរួមវិភាគទានផ្នែកនយោបាយ អាចជាផ្នែកមួយយ៉ាងសំខាន់ ក្នុងការគាំទ្រដល់ដំណើរការប្រជាធិបតេយ្យជាមួយនឹងធុរកិច្ច និងបុគ្គលនានាដែលបានផ្ដល់វិភាគទានហិរញ្ញវត្ថុដល់បេក្ខជន ឬដល់បុព្វហេតុនយោបាយដែលពួកគេគាំទ្រ។ ទោះជាយ៉ាងណាក្ដី ដូចគ្នាទៅនឹងបញ្ហាជាច្រើនដទៃទៀតដែរការចូលរួមវិភាគទានផ្នែកនយោបាយអាចងាយរងគ្រោះទៅនឹងការរំលោភបំពាននានា។ ជាពិសេស នៅពេលដែលការរួមវិភាគទានផ្នែកនយោបាយ ត្រូវបានគេមើលឃើញថាជាមធ្យោបាយមួយ ដើម្បីទទួលបានឥទ្ធិពល មិនសមស្រប ធុរកិច្ចអាចប្រឈមនឹងបញ្ហា។ ហេតុដូច្នេះ សាច់ប្រាក់ អំណោយ បដិសណ្ឋារកិច្ច ឬ ទម្រង់ផ្សេងៗទៀតនៃការចូលរួមចំណែកដល់គណបក្សនយោបាយ ឬបេក្ខជនអាចបង្កើតជាធាតុមួយដែលមានឥទ្ធិពលមិនសមស្របដែលធុរកិច្ចគប្បីព្យាយាមចៀសវាង។ អត្ថបទសង្ខេបអំពីធុរកិច្ចនេះពិភាក្សាអំពីគោលនយោបាយ និងនីតិវិធីនានាដែលក្រុមហ៊ុនគប្បីអនុវត្ត ដើម្បីកាត់បន្ថយការប្រឈមទៅនឹងហានិភ័យដែលពាក់ព័ន្ធនឹងការចូលរួមវិភាគទានផ្នែកនយោបាយ។

## តើការរួមវិភាគទានផ្នែកនយោបាយគឺជាអ្វី?

ការរួមវិភាគទានផ្នែកនយោបាយ ត្រូវបានកំណត់ថាជា ការរួមចំណែកជាហិរញ្ញវត្ថុ ឬជាសម្ភារៈដែលត្រូវបាន ផ្តល់ឱ្យក្នុងគោលបំណងគាំទ្រដល់បុព្វហេតុនយោបាយ។ ការចូលរួមវិភាគទានផ្នែកនយោបាយ អាចរួមបញ្ចូល ប្រាក់កម្ចីអំណោយជាទ្រព្យសម្បត្តិ សេវាកម្មការឧបត្ថម្ភដល់ព្រឹត្តិការណ៍ការផ្សាយពាណិជ្ជកម្ម ឬសកម្មភាពផ្សព្វផ្សាយ ឬការផ្តល់លិខិតគាំទ្រដល់គណបក្សនយោបាយណាមួយ។

**ឧទាហរណ៍** ក្រុមហ៊ុនរបស់អ្នកវិភាគទាន ៥០០ ដុល្លារអាមេរិក ដល់អ្នកនយោបាយក្នុងស្រុកដែលអ្នកកោតសរសើរនិងចង់គាំទ្រ។ ការអនុញ្ញាតឱ្យបុគ្គលិកឈប់សម្រាកដោយទទួលបានប្រាក់បៀវត្សរ៍ ដើម្បីចូលរួមធ្វើយុទ្ធនាការសម្រាប់បេក្ខជន ឬគណបក្សនយោបាយណាមួយ ក៏អាចចាត់ទុកថាជាការចូលរួមចំណែកផ្តល់វិភាគទានផ្នែកនយោបាយដែរ។

ការរួមវិភាគទានផ្នែកនយោបាយ ដែលត្រូវបានធ្វើឡើងសម្រាប់ហេតុផលស្របច្បាប់ ដូចជាការកោតសរសើរយ៉ាងពិតប្រាកដចំពោះអ្នកនយោបាយណាម្នាក់ និងចង់គាំទ្រដល់យុទ្ធនាការ របស់គាត់ត្រូវបានអនុញ្ញាតអោយធ្វើបាន។ បើទោះជាដូច្នេះក្តីការរួមចំណែកផ្តល់វិភាគទានផ្នែកនយោបាយ ដែលត្រូវបានធ្វើឡើងដើម្បីធានានូវកិច្ចព្រមព្រៀងធុរកិច្ច ឬ ដើម្បីទទួលបានឥទ្ធិពលមិនសមស្របក្នុងការទទួលបានកិច្ចសន្យា ឬកំណត់ទ្រង់ទ្រាយច្បាប់ ដើម្បីគាំទ្រដល់ធុរកិច្ចរបស់ខ្លួនមិនគួរត្រូវបានអនុញ្ញាតឡើយ។

# គោលនយោបាយ និងនីតិវិធី

ពេលខ្លះ ការរួមវិភាគទានផ្នែកនយោបាយ ត្រូវបានគ្រប់គ្រងដោយច្បាប់ ដូច្នេះវាជាគំនិតល្អសម្រាប់ ធុរកិច្ចក្នុងការពិនិត្យច្បាប់ពាក់ព័ន្ធ មុនពេលផ្តល់វិភាគទានផ្នែកនយោបាយ ។ ក្នុងករណីអវត្តមានច្បាប់ គោលនយោបាយ និងនីតិវិធីសមស្របស្តីពីការរួមវិភាគទានផ្នែកនយោបាយអាចជួយការពារក្រុមហ៊ុនពីការប្រព្រឹត្តខុសឆ្គង ។

គោលនយោបាយសមស្របទាក់ទងនឹងការរួមរួមវិភាគទានផ្នែកនយោបាយ គឺមិនអនុញ្ញាតិឱ្យមានវិភាគទានផ្នែកនយោបាយណាមួយ ដែលអាចនាំឱ្យមានឥទ្ធិពលអយុត្តិធមិឡើយ ។ រាល់និយោជិត បុគ្គលិក ភ្នាក់ងារ អន្តរការី អ្នកបញ្ចុះបញ្ចូល ឬក្រុមហ៊ុនខ្លួនឯងផ្ទាល់ មិនគួរធ្វើវិភាគទានដោយផ្ទាល់ ឬដោយប្រយោលដល់បុគ្គលឬអង្គការ ពាក់ព័ន្ធក្នុងនយោបាយ ក្នុងលក្ខណៈជាមធ្យោបាយដើម្បីទទួលបានផលប្រយោជន៍អយុត្តិធមិក្នុងប្រតិបត្តិការធុរកិច្ចឡើយ ។

សម្រាប់ហេតុផលនេះ គោលនយោបាយសុវត្ថិភាពមួយ គឺជាគោលនយោបាយដែលហាមឃាត់ការវិភាគទានផ្នែកនយោបាយ ។ ប្រសិនបើក្រុមហ៊ុនរបស់អ្នកមិនពេញចិត្តការវិភាគទានផ្នែកនយោបាយនេះ គេអាចផ្តល់អនុសាសន៍ឱ្យមានគោលនយោបាយនិងនីតិវិធីច្បាស់លាស់មួយ ។ ការសម្រេចចិត្តពាក់ព័ន្ធនឹងវិភាគទានផ្នែកនយោបាយ គប្បីធ្វើឡើងតាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលប្រសិនបើជាក្រុមហ៊ុនធំ ឬត្រូវបានកត់ត្រាត្រឹមត្រូវនៅក្នុងកំណត់ហេតុប្រជុំថ្នាក់ដឹកនាំសម្រាប់ក្រុមហ៊ុនតូចៗ ។ និយោជិតទាំងអស់គប្បីទទួលបានការជូនដំណឹងអំពីការព្រមព្រៀងក្នុងការចូលរួមវិភាគទាននយោបាយ ។

**សំណួរដែលក្រុមហ៊ុនរបស់អ្នកគប្បីសួរ៖ តើខ្ញុំកំពុងផ្តល់វិភាគទាននេះ ក្នុងគោលបំណងទទួលបានអ្វីម្យ៉ាងត្រឡប់មកវិញ ឬ តើខ្ញុំគ្រាន់តែចង់គាំទ្រគោលនយោបាយទាក់ទង នឹងនយោបាយដែលខ្ញុំជឿប៉ុណ្ណោះ?**

ក្រុមហ៊ុនគួរតែយកចិត្តទុកដាក់លើពេលវេលាប្រសិនបើរដ្ឋាភិបាលកំពុងតែពិនិត្យទៅលើកិច្ចសន្យា ឬ អាជ្ញាប័ណ្ណ នោះវាប្រហែលជាមិនមែនជាពេលវេលាសមស្របដើម្បីចូលរួមវិភាគទាននយោបាយនោះឡើយ ។ រាល់ការរួមវិភាគទានផ្នែកនយោបាយទាំងអស់គប្បីបង្ហាញជាសាធារណៈ ។ ក្រុមហ៊ុនអាចបង្ហាញពីវិភាគទានផ្នែកនយោបាយនៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ពួកគេ ឬ គ្រាន់តែកត់ត្រានៅក្នុងបញ្ជីគណនេយ្យធុរកិច្ច ។

ចំណុចគួរពិចារណា៖

១. ប្រសិនបើធ្វើការរួមវិភាគទានផ្នែកនយោបាយអ្នកត្រូវពិចារណាពីពេលវេលា។ តើក្រុមហ៊ុនរបស់អ្នកត្រូវការកិច្ចសន្យា ឬអាជ្ញាប័ណ្ណរបស់រដ្ឋាភិបាលឬទេ?

២. ត្រូវប្រាកដក្នុងការទទួលបានសេចក្ដីសម្រេចពីក្រុមប្រឹក្សាភិបាល ឬ កិច្ចព្រមព្រៀងមួយនៅក្នុងកំណត់ហេតុប្រជុំថ្នាក់ដឹកនាំ (ប្រសិនបើជាក្រុមហ៊ុនតូច)។

៣. ត្រូវធានាថាបុគ្គលិកទាំងអស់នៅក្នុងក្រុមហ៊ុន ដឹងពីការចូលរួមវិភាគទានផ្នែកនយោបាយ។

៤. កត់ត្រាអំពីការរួមវិភាគទាននៅក្នុងរបាយការណ៍គណនេយ្យរបស់អ្នក ឬបញ្ចូលវាទៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់អ្នក។

## តើអត្ថប្រយោជន៍នៃគោលនយោបាយស្ដីពីការរួមវិភាគទានផ្នែកនយោបាមានអ្វីខ្លះ?

ការមានគោលនយោបាយនិងនីតិវិធីច្បាស់លាស់តែងតែជាគំនិតល្អនៅពេល ដែលព្យាយាមការពារធុរកិច្ចរបស់អ្នកពីហានិភ័យពាក់ព័ន្ធនឹងអំពើពុករលួយ។ អត្ថប្រយោជន៍ផ្សេងទៀតរួមមានចំណេះដឹង និងការយល់ដឹងច្បាស់លាស់របស់បុគ្គលិក វិធីសាស្ត្រគណនេយ្យភាពដែលល្អប្រសើរ យន្តការឆ្លើយតបទៅនឹងសំណើសម្រាប់វិភាគទានផ្នែកនយោបាយនិងជារួមគឺការអនុវត្តធុរកិច្ចស្អាតស្អំ។ គោលនយោបាយទាំងនេះនឹងជួយធានាថាក្រុមហ៊ុនមិនទទួលបានឥទ្ធិពលមិនសមស្របណាមួយតាមរយៈវិភាគទានរបស់ពួកគេចំពោះអ្នកនយោបាយឬគណបក្សនយោបាយនោះទេ។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងមកកាន់៖ piseypech@ticambodia.org ។

# ផ្នែកទី៣៖
# ការសច្ចាប្រព្រឹត្តសុចរិតភាព

ការសច្ចាប្រព្រឹត្តសុចរិតភាព ជួយនាំមកនូវតម្លៃស្នូលរបស់ក្រុមហ៊ុនអំពីសុចរិតភាព និងកំណត់បទដ្ឋាន សីលធម៌នៃធុរកិច្ចដែលបុគ្គលិកទាំងអស់ត្រូវបានស្នើសុំឱ្យគាំទ្រ អនុម័ត និងបញ្ចូលក្នុងគ្រប់សកម្មភាពធុរកិច្ចទាំងអស់។ ការសច្ចានេះ ក៏បញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុនចំពោះបទដ្ឋានខ្ពស់បំផុតនៃក្រមសីលធម៌វិជ្ជាជីវៈ និងផ្តល់ការណែនាំក្នុងការធ្វើសកម្មភាព ឬការសម្រេចចិត្តក្នុងនាមក្រុមហ៊ុន ដោយគ្មានការយោគយល់ទាក់ទងនឹងបញ្ហាសុចរិតភាព។

**តើការសច្ចាប្រព្រឹត្តសុចរិតភាពគឺជាអ្វី?**

ការសច្ចាប្រព្រឹត្តសុចរិតភាព គឺជាសកម្មភាពស្ម័គ្រចិត្តដែលក្រុមហ៊ុននីមួយៗ គួរអនុវត្តដើម្បីធ្វើការប្រកាសជាឯកតោភាគីប្រឆាំងនឹងការប្រព្រឹត្តអំពើពុករលួយ និងសម្តែងពីការសម្រេចចិត្តរបស់ខ្លួនដើម្បីធ្វើការឆ្ពោះទៅរកបរិយាកាសធុរកិច្ចដែលមានគោលការណ៍ខ្ពស់។

ការសច្ចាប្រព្រឹត្តសុចរិតភាពនេះ លើកកម្ពស់នូវវប្បធម៌តម្លាភាព និងបង្កើតឱ្យមានការតម្រង់ទិសច្បាស់លាស់សម្រាប់បុគ្គលិកដើម្បីអនុលោមទៅតាមច្បាប់និងបទបញ្ញត្តិនានា នៅខណៈពេលដែលពួកគេធ្វើការជាមួយដៃគូអ្នកផ្គត់ផ្គង់ភ្នាក់ងាររដ្ឋាភិបាលនិងអ្នកម៉ៅការ។ វាក៏បង្ហាញផងដែរនូវការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុន និងបុគ្គលិករបស់ខ្លួនក្នុងការលើកកម្ពស់គណនេយ្យភាព តម្លាភាព និងសុចរិតភាពនៅក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ពួកគេហើយបង្កើតប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងតាមដានការផ្គត់ផ្គង់ឱ្យបានដិតដល់និងគោរពតាមច្បាប់ដែលមានស្រាប់។

បុគ្គលិករបស់ក្រុមហ៊ុននៅគ្រប់កម្រិតទាំងអស់ គួរតែត្រូវបានស្នើសុំឱ្យចុះហត្ថលេខាលើកា រ សច្ចាប្រព្រឹត្តសុចរិតភាពដើម្បីប្តេជ្ញាគោរពតាមបទដ្ឋានសីលធម៌និងសុជីវធម៌ខ្ពស់បំផុត។ លើ សពីនេះទៀត អគ្គនាយកប្រតិបត្តិឬអ្នកកាន់តំណែងសមមូលក៏គប្បីប្តេជ្ញាគោរពតាមបទដ្ឋានទាំងនេះផងដែរ។ អត្ថបទនេះនឹងចែករំលែកជាមួយក្រុមហ៊ុននូវគោលការណ៍និងការហាមឃាត់ដែលតម្រូវឱ្យបុគ្គលិក និងអ្នកគ្រប់គ្រងទាំងអស់គប្បីលើកកម្ពស់នៅក្នុងប្រតិបត្តិការធុរកិច្ចរបស់ពួកគេ។

# គោលការណ៍ និងបម្រាមនៃការសច្ចាប្រព្រឹត្តិសុចរិតភាព

ជាការសំខាន់ណាស់ ដែលការសច្ចាប្រព្រឹត្តិសុចរិតភាព តម្រូវឱ្យធ្វើពីលើចុះក្រោម អាស្រ័យដោយសកម្មភាពនេះបង្ហាញថា អគ្គនាយកប្រតិបត្តិរបស់ក្រុមហ៊ុន ត្រូវបានកំណត់ឱ្យដឹកនាំដោយធ្វើជាគម្រូគេ តាមរយៈការបង្ហាញពីគុណតម្លៃសីលធមិនិងសុជីវធម៌ដ៏រឹងមាំ ក្នុងអំឡុងពេលនៃការដឹកនាំរបស់ពួកគេ។ វិធីសាស្ត្រពីលើចុះក្រោមខាងលើនេះ គឺជាមូលដ្ឋានព័ត៌មានសម្រាប់បុគ្គលិកទាំងអស់ឱ្យយល់អំពីគុណតម្លៃក្រមសីលធមិរបស់ក្រុមហ៊ុន។

ថ្នាក់គ្រប់គ្រង គួរតែលើកកម្ពស់គុណតម្លៃនៃគណនេយ្យភាពភាពស្មោះត្រង់ និងសុចរិតភាព ហើយព្យាយាមបង្កើតឱ្យមាននៅក្នុងវប្បធមិរបស់ក្រុមហ៊ុន និងក្នុងទំនាក់ទំនងជាមួយបុគ្គលិក ដៃគូពាណិជ្ជកម្ម អតិថិជន និងអ្នកពាក់ព័ន្ធដទៃទៀត។ ទន្ទឹមនឹងនេះ បុគ្គលិកក្រុមហ៊ុនគួរតែដឹងថា អំពើពុករលួយ គឺជាបទល្មើស ហើយយល់ដឹងអំពីកាតព្វកិច្ចរបស់ក្រុមហ៊ុនក្នុងការអនុវត្តតាមច្បាប់ប្រឆាំងនឹងសំណូកនៅក្នុងប្រទេសកម្ពុជា។ បុគ្គលិកទាំងអស់គួរទទួលស្គាល់ និងប្រកាន់ខ្ជាប់នូវការប្ដេជ្ញាចិត្តរបស់ក្រុមហ៊ុនចំពោះគោលនយោបាយមិនអត់ឱនដាច់ខាតចំពោះអំពើពុករលួយ និងធ្វើសកម្មភាពគ្រប់ពេលវេលាដោយយុត្តិធមិ និងដោយស្មោះត្រង់។

ការប្ដេជ្ញាចិត្តមួយចំនួនដែលបានដាក់បញ្ចូលទៅក្នុងការសច្ចាប្រព្រឹត្តសុចរិតភាពទាមទារឱ្យអគ្គនាយកប្រតិបត្តិរបស់ក្រុមហ៊ុន ឬ ថ្នាក់ដឹកនាំជាន់ខ្ពស់អនុវត្តដូចខាងក្រោម៖

អនុវត្តធុរកិច្ចទាំងអស់ក្នុងលក្ខណៈមួយប្រកបដោយភាពយុត្តិធមិ ស្មោះត្រង់ និងតម្លាភាព។

ប្ដេជ្ញាបង្កើតគម្រូមួយតាមរយៈការប្រព្រឹត្តប្រកបដោយក្រមសីលធមិដើម្បីលើកកម្ពស់សុចរិតភាព និងអភិបាលកិច្ចល្អព្រមទាំងធ្វើអ្វីៗគ្រប់យ៉ាងដែលពួកគេអាចធ្វើបានដើម្បីធានាថា អ្នកដែលធ្វើការនៅក្រោមពួកគេ ប្រហាក់ប្រហែលពួកគេ និងថ្នាក់លើពួកគេធ្វើសកម្មភាពដោយសុឆន្ទៈ ស្មោះត្រង់ សុចរិតភាព និងប្រកបដោយអភិបាលកិច្ចល្អ។

អនុវត្តតាមក្រមសីលធមិ និងកម្មវិធីសុចរិតភាពរបស់ក្រុមហ៊ុន។

ប្រកាសពីទំនាស់ផលប្រយោជន៍ណាមួយដែលអាចកើតឡើងក្នុងកំឡុងពេលអនុវត្តភារកិច្ចរបស់ខ្លួន។

ទាំងអគ្គនាយកប្រតិបត្តិ និងបុគ្គលិកទាំងអស់ មិនគួរផ្តល់ ឬទទួលយកសំណូក ឬចូលរួមក្នុងទម្រង់នៃការប្រព្រឹត្តអំពើពុករលួយណាមួយ ដូចដែលបានកំណត់ក្នុងក្រមព្រហ្មទណ្ឌ និងនៅក្រោមជំពូកទី ៦ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយរបស់ព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១០ឡើយ។ ក្នុងស្ថានភាពដែលអគ្គនាយកប្រតិបត្តិទទួលបានការផ្តល់ជូន អូសទាញ ឬបង្ខំឱ្យទទួលយក ឬផ្តល់សំណូក ឬបុគ្គលិកដឹងអំពីអំពើពុករលួយណាមួយ និងការប្រព្រឹត្តគ្មានក្រមសីលធម៌ដទៃទៀត ពួកគេគប្បីរាយការណ៍ទៅអាជ្ញាធរពាក់ព័ន្ធ។ លើសពីនេះទៀត ពួកគេគប្បីផ្តល់ការគាំទ្រ និងជំនួយពេញលេញ និងប្រកបដោយសង្គតភាពដល់អាជ្ញាធរមានសមត្ថកិច្ចសមស្រប ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។

គោលនយោបាយទាំងនេះ ត្រូវបានអនុវត្តជាសកលចំពោះក្រុមប្រឹក្សាភិបាលអ្នកគ្រប់គ្រង និងបុគ្គលិករបស់ក្រុមហ៊ុន និងក្រុមហ៊ុន ដែលជាសម្ព័ន្ធភាពរបស់ខ្លួន ស្របតាមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយរបស់ប្រទេស។ គោលការណ៍ និងការហាមឃាត់ទូទៅ ក៏អនុវត្តផងដែរចំពោះទីប្រឹក្សា និងភាគីទីបីដទៃទៀត ដែលធ្វើការនៅក្នុងនាមក្រុមហ៊ុន ក៏ដូចជាអ្នកផ្គត់ផ្គង់ និងដៃគូ ឬភាគីពាក់ព័ន្ធដែលធ្វើការជាមួយធុរកិច្ច។



រក្សាសិទ្ធិរូបភាពដោយ Creative Common, Sarahhoa

# ទណ្ឌកម្មចំពោះភាពមិនអនុលោម

ប្រសិនបើមានបុគ្គលិកណាម្នាក់បំពានលើការប្តេជ្ញាចិត្ត និង/ឬ ការប្រកាសខាងលើក្រុមហ៊ុនអាចដាក់ទណ្ឌកម្មទៅលើពួកគេដូចខាងក្រោម៖



ការព្រមានជាលាយលក្ខណ៍អក្សរ



ការដកហូតអត្ថប្រយោជន៍ផ្សេងៗពីការងារ



ការពន្យារពេលតម្លើងបៀវត្សរ៍



ការកាត់បន្ថយបៀវត្សរ៍



ការទម្លាក់តំណែង



ការបញ្ឈប់ពីការងារ

## អត្ថប្រយោជន៍នៃការមាន និងការអនុវត្តការសច្ចាប្រព្រឹត្តសុចរិតភាព

មានអត្ថប្រយោជន៍សំខាន់ៗចំនួនបីសម្រាប់ក្រុមហ៊ុនឯកជន ឬអង្គការ ដែលមាន និងអនុវត្តសមស្របនូវការសច្ចាប្រព្រឹត្តសុចរិតភាព រួមមានជាអាទិ៍៖

បញ្ជូនសារទៅភាគីពាក់ព័ន្ធទាំងអស់ថាក្រុមហ៊ុនមិនអធ្យាស្រ័យចំពោះទម្រង់នៃសំណូក/អំពើពុករលួយណាមួយឡើយ ។

ទាក់ទាញការវិនិយោគបរទេស ។

បង្កើតនូវវប្បធម៌សុចរិតភាពនៅក្នុងប្រតិបត្តិការធុរកិច្ចដែលនាំឱ្យក្រុមហ៊ុនមានកេរ្តិ៍ឈ្មោះធុរកិច្ចល្អនិងសន្សំសំចៃការចំណាយ ។

បន្ថែមលើការអនុវត្តការសច្ចាប្រព្រឹត្តសុចរិតភាពនៅក្នុងក្រុមហ៊ុន ក្រុមហ៊ុនខ្លួនឯងអាចពិចារណាចុះហត្ថលេខាលើការសច្ចាប្រព្រឹត្តសុចរិតភាព ដែលបង្កើតឡើងដោយសមាគមអន្តរជាតិ ឬបណ្តាញដទៃទៀត ដោយទង្វើបែបនេះនឹងផ្សព្វផ្សាយ ដល់សាធារណជនជាពិសេសដល់អ្នកវិនិយោគបរទេស ដែលតម្កល់តម្លៃរបស់ពួកគេលើការអនុវត្តធុរកិច្ចស្អាតស្អំ និងសុចរិតភាព។ ថ្មី ៗនេះបណ្តាញទំនួលខុសត្រូវខាងសង្គមរបស់សាជីវកម្មអាស៊ាន (ASEAN CSR Network) បានប្រកាសផ្សព្វផ្សាយពីការលើកកម្ពស់សុចរិតភាពថ្នាក់តំបន់របស់ខ្លួនដែលបើកចំហសម្រាប់ក្រុមនានាដូចជា វិស័យឯកជន វិស័យសាធារណៈ សង្គមស៊ីវិល និងអង្គការអន្តរជាតិដើម្បីចូលរួម។ សម្រាប់ព័ត៌មានបន្ថែមសូមចូលមើល http://ingrity hasnoborders.com/integrity-pledge/what-is-integrity-pledge ។

សម្រាប់ព័ត៌មានលម្អិតបន្ថែមនិងដើម្បីទទួលបានកាគាំទ្រក្នុងការរៀបចំសេចក្តីព្រាងការសច្ចាប្រព្រឹត្តសុចរិតភាព សូមទាក់ទងមកកាន់៖ piseypech@ticambodia.org ។



រក្សាសិទ្ធិរូបភាពដោយ Creative Common, Michael Coghlan

# ផ្នែកទី៤៖
# អំណោយសប្បុរសធម៌ និងការឧបត្ថម្ភ

អំណោយសប្បុរសធម៌ និងការឧបត្ថម្ភនានា គឺជាទំនួលខុសត្រូវសង្គមផង និងជាយុទ្ធសាស្ត្រទីផ្សារផង សម្រាប់ក្រុមហ៊ុននីមួយៗក្នុងការរួមចំណែកដល់សង្គមហើយស្របពេលជាមួយគ្នានោះក៏កសាងបានផងដែរ នូវកេរ្តិ៍ឈ្មោះរបស់ពួកគេជាសាធារណៈនិងនៅក្នុងវិស័យធុរកិច្ច។ ជារៀងរាល់ឆ្នាំ ក្រុមហ៊ុនមួយចំនួនបានបម្រុងទុកថវិកាខ្លះៗ ដែលត្រូវបែងចែកសម្រាប់សកម្មភាពសង្គមនៅក្នុងទម្រង់ផ្សេងៗ ដូចជាសាច់ប្រាក់ ការឧបត្ថម្ភជាសម្ភារៈ ឬសេវាកម្មដែលជានិមិត្តរូបនៃការគោរពចំពោះរដ្ឋាភិបាល ដៃគូពាណិជ្ជកម្ម អង្គការសប្បុរសធម៌ ឬសម្រាប់ជាផលប្រយោជន៍ដល់ប្រជាពលរដ្ឋទូទៅ។

សហគ្រាសដែលធ្វើការចូលរួមវិភាគទានសង្គមដោយគ្មានគោលនយោបាយច្បាស់លាស់ ឬកំពុងខិតខំដើម្បីបង្កើនឥទ្ធិពលរបស់ពួកគេអាចត្រូវបានបកស្រាយថាជាប់ពាក់ព័ន្ធក្នុងអំពើពុករលួយដោយចេតនា ឬអចេតនា។ បញ្ហាជាច្រើនកើតឡើងនៅពេលមានការបរិច្ចាគអំណោយ និងការឧបត្ថម្ភនានាយ៉ាងច្រើនលើសលប់ បន្ទាប់ពីបានទទួលសំណើរបស់មន្ត្រីសាធារណៈ ឬអ្នកដែលជាភាគីទីបីជាមួយនឹងការរំពឹងទុកថា នឹងទទួលបាននូវអ្វីមួយត្រឡប់មកវិញ។

សេចក្តីសង្ខេបស្តីពីធុរកិច្ចនេះ នឹងផ្តល់ការណែនាំដល់ក្រុមហ៊ុននានាអំពីគោលនយោបាយ និងនីតិវិធីសមស្របដើម្បីអនុវត្តតាម នៅពេលទទួលបានសំណើសុំជំនួយសប្បុរសធម៌ ឬការឧបត្ថម្ភនានា។

## តើអំណោយសប្បុរសធម៌ និងការឧបត្ថម្ភគឺជាអ្វី និងមានហានិភ័យអ្វីខ្លះ?

អំណោយសប្បុរសធម៌ អាចត្រូវបានគេធ្វើឡើងក្នុងទម្រង់ជាហិរញ្ញវត្ថុ ឬ ជាសម្ភារៈ ក្នុងគោលបំណងដើម្បី គាំទ្រដល់បុព្វហេតុដ៏មានតម្លៃ និងចាំបាច់តាមរយៈអង្គការសប្បុរសធម៌ដែលបានចុះបញ្ជី។ អំណោយសប្បុរសធម៌ទាំងនេះ រួមមានប្រាក់កម្ចីអំណោយជាទ្រព្យសម្បត្តិ សេវាកម្មការឧបត្ថម្ភជាសម្ភារៈនៅក្នុងព្រឹត្តិការណ៍ណាមួយសកម្មភាពផ្សាយពាណិជ្ជកម្ម ឬលើកកម្ពស់គាំទ្រដល់អង្គការសប្បុរសធម៌។ ការដែលអនុញ្ញាតឱ្យនិយោជិតចាកចេញក្នុងម៉ោងការងារដើម្បីចូលរួមធ្វើសកម្មភាពសប្បុរសធម៌ ក៏ចាត់ទុកថារួមចំណែកជាការបរិច្ចាគផងដែរ។

អំណោយសប្បុរសធម៌អាចមានហានិភ័យទាក់ទងនឹងអំពើសូកប៉ាន់អាស្រ័យដោយវាពាក់ព័ន្ធនឹងការផ្ដល់ប្រាក់ជូនភាគីទីបី ដោយពុំមានការតបស្នងមកវិញច្បាស់លាស់ និងអាចត្រូវបានប្រើប្រាស់ជាលេសបិទបាំងអំពើសូកប៉ាន់ ។អំណោយនានាអាចត្រូវបានស្នើសុំ ឬ ផ្ដល់ឱ្យសម្រាប់គោលបំណងពុករលួយជូនដល់អង្គការសប្បុរសធម៌ស្ថាប័នកីឡា ឬ អង្គការមនុស្សជាតិ "ជួរមុខ" ឬត្រូវបានគេប្រើប្រាស់ដើម្បីបង្កើតឥទ្ធិពលមិនសមស្របតាមរយៈការបរិច្ចាគជាបុព្វហេតុដើម្បីបំពេញចិត្តអ្នកធ្វើសេចក្ដីសម្រេច ឬអតិថិជន។ អំណោយដែលបានផ្ដល់ជូនតាមរយៈអន្តរការីមានហានិភ័យបន្ថែមទៀតអាស្រ័យដោយវាអាចជាកម្មវត្ថុនៃការកាត់បន្ថយការត្រួតពិនិត្យ និងការតាមដាន។

ខុសពីអំណោយសប្បុរសធម៌ជាទូទៅការឧបត្ថម្ភនានាត្រូវបានធ្វើឡើងសម្រាប់ទិសដៅធុរកិច្ច ដូចជា លើកកម្ពស់ ម៉ាកយីហោផលិតផលឬគោលបំណងបង្កើនកេរ្តិ៍ឈ្មោះ។ ការឧបត្ថម្ភអាចជាការផ្ដល់ហិរញ្ញប្បទាន គាំទ្រមួយផ្នែកដល់គម្រោង ឬព្រឹត្តិការណ៍ណាមួយដែលអនុវត្តដោយបុគ្គល ឬអង្គការមួយផ្សេងទៀត។ សកម្មភាពនេះអាចបង្ហាញឱ្យឃើញអំពីហានិភ័យនៃអំពើសូកប៉ាន់ដោយសារវាទាក់ទងនឹងការបង់ប្រាក់សម្រាប់អត្ថប្រយោជន៍ណាមួយ ដែលជារឿយៗ ពិបាកក្នុងការ វាស់វែង និងតាមដាន។ ការឧបត្ថម្ភអាចជាកម្មវត្ថុនៃការផ្ដល់សំណូក។ មូលនិធិអាចត្រូវបានបង្វែរប្រើប្រាស់សម្រាប់គោលបំណងពុករលួយជូនដល់អង្គការសប្បុរសធម៌ ស្ថាប័នកីឡា ឬអង្គការមនុស្សជាតិ "ជួរមុខ"។ មូលនិធិទាំងនោះក៏អាចត្រូវបានប្រើប្រាស់ដើម្បីបង្កើតឥទ្ធិពលមិនសមស្របតាមរយៈការឧបត្ថម្ភដល់បុព្វហេតុ នៃការបំពេញបំណងអ្នកធ្វើសេចក្ដីសម្រេច ឬ អតិថិជនផងដែរ។

# គោលនយោបាយ និងនីតិវិធីស្តីពីអំណោយសប្បុរសធម៌ និងការឧបត្ថម្ភ

អំណោយសប្បុរសធម៌ និងការឧបត្ថម្ភសម្រាប់ហេតុផលស្របច្បាប់ ត្រូវបានរឹតបន្តឹងក្នុងករណីដែលសកម្មភាពនេះត្រូវបានធ្វើឡើងដើម្បីធានាសម្រេចឱ្យបាននូវគម្រោងរបស់ធុរកិច្ច ឬវិភាគទានដែលពាក់ព័ន្ធទៅនឹងគណបក្សនយោបាយមិនថាស្ថិតនៅក្នុងទម្រង់បែបណាឡើយ ទោះជាត្រូវបានធ្វើដោយផ្ទាល់ឬដោយប្រយោលក្តី។ យ៉ាងណាវិញ ក្រុមហ៊ុនខ្លះអាចអនុញ្ញាតឱ្យមានវិភាគទានផ្នែកនយោបាយ ប៉ុន្តែដើម្បីកុំឱ្យមានការលើកទឹកចិត្ត និងដើម្បីទប់ស្កាត់ការកេងប្រវ័ញ្ចក្នុងទម្រង់ណាមួយ រាល់ការចំណាយទាំងអស់ ត្រូវតែភ្ជាប់មកជាមួយនូវបង្កាន់ដៃទទួលប្រាក់ពីអ្នកទទួល។ នីតិវិធីគឺអាស្រ័យលើបរិមាណដែលបានស្នើសុំសម្រាប់ការបរិច្ចាគ ឬ ការ ឧបត្ថម្ភ និងអាស្រ័យលើគោលនយោបាយ ឬបរិបទដែលមានស្រាប់របស់ក្រុមហ៊ុន។ គោលនយោបាយសម្រាប់ការបរិច្ចាគ និងឧបត្ថម្ភអាចត្រូវបានកំណត់ទៅតាមភាព ជាក់ស្តែង។

បុគ្គលទាំងអស់ ឬអង្គការនានាដែលបានស្នើសុំវិភាគទាន ត្រូវតែបំពេញទម្រង់បែបបទស្នើសុំអំណោយសប្បុរសធម៌ និងការឧបត្ថម្ភ ហើយបញ្ជូនសំណើនេះទៅប្រធានគ្រប់គ្រងផ្នែកសុចរិតភាព តាមរយៈអ៊ីម៉ែល ឬ ដោយផ្ទាល់។ក្រោយពេលទទួលបានទម្រង់បែប បទស្នើសុំ ប្រធានគ្រប់គ្រងផ្នែកសុចរិតភាពត្រូវធ្វើការត្រួតពិនិត្យសាវតានៃការស្នើសុំក្នុងរយៈពេលប្រាំថ្ងៃនៃថ្ងៃធ្វើការ។ ការត្រួតពិនិត្យ នឹងគ្របដណ្តប់លើទិដ្ឋភាពជាក់លាក់បីក្នុងលក្ខខណ្ឌរបស់អង្គការ ឬស្ថាប័នទទួល៖ ១) ភាពពិតជាក់ស្តែងរបស់អង្គការ ២) ការរួមវិភាគទានមិនត្រូវធ្វើឡើងដើម្បីធានាសម្រេចឱ្យ បាននូវកិច្ចសន្យាធុរកិច្ច និង ៣) អង្គការទទួលត្រូវតែមិនមែនជាគណបក្សនយោបាយ។



រក្សាសិទ្ធិរូបភាពដោយ Creative Common, Mohd Fazlin Mohd Effendy Ooi

បន្ទាប់ពីបញ្ចប់ការត្រួតពិនិត្យប្រវត្តិសាវតា ប្រធានគ្រប់គ្រងផ្នែកសុចរិតភាពនឹងដាក់ជូនសំណើពាក្យសុំនេះទៅអាជ្ញាធរដោយឡែកពីគ្នាដែលជាអ្នកធ្វើការសម្រេចចិត្ត។ ដើម្បីអនុម័តលើចំនួនថវិកាដែលនឹងត្រូវធ្វើប្រតិបត្តិការ អគ្គនាយកប្រតិបត្តិក្រុមហ៊ុនប្រធានគ្រប់គ្រងផ្នែកសុចរិតភាព ក្រុមប្រឹក្សាភិបាល ឬនាយកដ្ឋានហិរញ្ញវត្ថុគប្បីចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចនេះ។

ក្រុមហ៊ុនកសិកម្មមួយដែលមានមូលដ្ឋាននៅប្រទេសកម្ពុជាបានអនុវត្តគោលនយោបាយស្តីពីអំណោយសប្បុរសធម៌ និងការឧបត្ថម្ភ ដោយផ្អែកលើបរិបទរបស់ក្រុមហ៊ុន។ ក្នុងករណីនេះ អគ្គនាយកប្រតិបត្តិ គឺជាអ្នកធ្វើសេចក្តីសម្រេច សម្រាប់ការបរិច្ចាគ ឬការឧបត្ថម្ភ រហូតដល់ ១,៥០០ ដុល្លារអាមេរិក ដោយឡែក ក្រុមប្រឹក្សាភិបាលមានសិទ្ធិអនុម័តប្រសិនបើចំនួនទឹកប្រាក់លើសពី ១,៥០០ ដុល្លារអាមេរិក និងតិចជាង ៥,០០០ ដុល្លារអាមេរិក។ ប្រសិនបើលើសពី ៥,០០០ ដុល្លារអាមេរិកការអនុម័ត ត្រូវមានការពិនិត្យផ្ទៀងផ្ទាត់ពីប្រធានគ្រប់គ្រងផ្នែកសុចរិតភាពនិងអគ្គនាយកប្រតិបត្តិរហូតដល់ក្រុមប្រឹក្សាភិបាល។



រក្សាសិទ្ធិរូបភាពដោយ Creative Common, Electrostatico

សម្រាប់ប្រតិបត្តិការទោលណាមួយដែលមានចំនួន ទឹកប្រាក់ច្រើនជាង ១,០០០ ដុល្លារអាមេរិក អ្នកទទួលផលត្រូវតែអនុវត្ត តាមនីតិវិធីដើម្បីស្នើសុំចំនួនទឹកប្រាក់នោះនិងត្រូវធ្វើរបាយការណ៍សង្ខេប ប័ណ្ណទទួល ប្រាក់ ឬ របាយការណ៍សវនកម្មប្រចាំឆ្នាំ បន្ទាប់ពីការបរិច្ចាគត្រូវបានធ្វើឡើង ។ សូមមើលប្រអប់ទី ១។

ប្រអប់ទី១៖

| ចំនួនថវិកា | អ្នកធ្វើសេចក្ដីសម្រេច |
|---|---|
| ១,៥០០ដុល្លារអាមេរិក | អគ្គនាយកប្រតិបត្តិ |
| ច្រើនជាង > ១,៥០០ដុល្លារអាមេរិក< ៥,០០០ដុល្លារអាមេរិក | ក្រុមប្រឹក្សាភិបាល |
| ៥,០០០ដុល្លារអាមេរិក | ចាប់ពីអ្នកគ្រប់គ្រងសុចរិតភាព ទៅក្រុមប្រឹក្សាភិបាល |

ប្រសិនបើពាក្យសុំត្រូវបានបដិសេធ ប្រធានគ្រប់គ្រងផ្នែកសុចរិតភាព ត្រូវផ្ញើលិខិតបដិសេធដល់អ្នកស្នើសុំក្នុងរយៈពេលប្រាំថ្ងៃនៃថ្ងៃធ្វើការចាប់ពីថ្ងៃដែលសេចក្ដីសម្រេចត្រូវបានធ្វើឡើង។ បើទោះជាដូច្នេះក្ដីប្រសិនបើពាក្យសុំត្រូវបានអនុម័តប្រធានគ្រប់គ្រងផ្នែកសុចរិតភាព ត្រូវបញ្ជូនសេចក្ដីសម្រេចទៅនាយកដ្ឋានហិរញ្ញវត្ថុ ដើម្បីរៀបចំការចំណាយសមស្រប ហើយត្រូវបានផ្ដល់ជូនក្នុងរយៈពេលដប់ថ្ងៃ បន្ទាប់ពីការអនុម័តពីប្រធាន ។នៅពេលការទូទាត់បានធ្វើរួចហើយ ត្រូវមានវិក្កយប័ត្រធ្វើការកត់ត្រាទុកនិងរៀបចំទុកជាឯកសារកាលប្បវត្ត។

## អត្ថប្រយោជន៍នៃការមានគោលនយោបាយស្តីពីអំណោយសប្បុរសធម៌ និងការឧបត្ថម្ភ

ក្រុមហ៊ុនទាំងឡាយ ដែលបានកំណត់គោលនយោបាយនិងដែនកំណត់ច្បាស់លាស់សម្រាប់ការឧបត្ថម្ភ និងការបរិច្ចាគសប្បុរសធម៌ នឹងទទួលបាននូវអត្ថប្រយោជន៍ទៅវិញទៅមក ព្រមទាំងគេចផុតពីការប្រព្រឹត្តអំពើសូកប៉ាន់ឬអំពើពុករលួយ។ គោលនយោបាយផ្ទៃក្នុង នឹងជួយកាត់បន្ថយជាអតិបរមានូវឥទ្ធិពលមិនសមស្របពីដៃគូរធុរកិច្ច ឬ អាជ្ញាធរដោយសារអ្នកស្នើសុំអាចដឹង និងយល់អំពីគោលនយោបាយរបស់ក្រុមហ៊ុនមុនពេលធ្វើការស្នើសុំអំណោយ ឬការឧបត្ថម្ភ។ បើគ្មានគោលនយោបាយទាំងនេះទេ ក្រុមហ៊ុនទាំងនោះនឹងប្រឈមសម្ពាធពីខាងក្រៅខណៈពេលដែលពួកគេកំពុងបន្តលូតលាស់ និងរីកចម្រើន។

គោលនយោបាយទាំងនេះ មិនត្រឹមតែទប់ស្កាត់ហានិភ័យនៅពេលអនាគតប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជួយកាត់បន្ថយផងដែរនូវកង្វះការវិនិច្ឆ័យ ព្រមទាំងធានាបាននូវ តម្លាភាព និងភាពត្រឹមត្រូវក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងផែនការថវិកា ដោយបែងចែកបាននូវកញ្ចប់ជំនួយនានាដល់សកម្មភាពសង្គមប្រកបដោយប្រសិទ្ធិភាព និងអនុញ្ញាតឱ្យមានការចំណាយត្រឹមត្រូវ។ ដូច្នេះការយល់ដឹងអំពីការគ្រប់គ្រង អំណោយ សប្បុរសធម៌ និងជំនួយឧបត្ថម្ភ ត្រូវបានបញ្ជាក់ជាមុនជាមួយភាគីទីបី ដើម្បីចៀសវាងការប្រព្រឹត្តមិនត្រឹមត្រូវ ឬមានឥទ្ធិពលលើអ្នកធ្វើសេចក្តីសម្រេច។ ការមានគោលនយោបាយស្តីពីការឧបត្ថម្ភ និងអំណោយសប្បុរសធម៌រឹងមាំ នឹងបង្កើតបានជា រនាំងមួយ ដើម្បីការពារក្រុមហ៊ុនពីការកេងប្រវ័ញ្ចនិងនាំមុខគេក្នុងវប្បធម៌សុចរិតភាព!

សម្រាប់ព័ត៌មានបន្ថែម និងដើម្បីទទួលបានការគាំទ្រលើការធ្វើសេចក្តីព្រាងគោលនយោបាយស្តីពីអំណោយសប្បុរសធម៌ និងការឧបត្ថម្ភសម្រាប់ក្រុមហ៊ុនរបស់អ្នកសូមទាក់ទងមកកាន់៖ piseypech@ticambodia.org ។

អង្គការតម្លាភាពកម្ពុជា
អាសយដ្ឋាន ៖ ផ្ទះលេខ៣ ផ្លូវ៣៩០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០២៣ ២១៤ ៤៣០   គេហទំព័រក្នុងប្រទេស ៖ www.ticambodia.org
គេហទំព័រនៅការិយាល័យកណ្តាល៖ www.transparency.org

រក្សាសិទ្ធិដោយ អង្គការតម្លាភាពកម្ពុជា ២០១៧